ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ:.....០០៥.../១៨.....គ.ជ.ប.ជ

# របាយការណ៍បូកសរុប
## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខែតុលា និងទិសដៅខែវិច្ឆិកា ឆ្នាំ២០១៨

## I. ស្ថានភាពទូទៅ

ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាប ជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័ន ជាសមាជិក គ.ជ.ប.ជ និងអង្គភាពពាក់ព័ន្ធនានា រួមទាំងលេខាធិការដ្ឋានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ)។ ក្រោយពីរាជរដ្ឋាភិបាលថៃបានចេញគោលការណ៍រឹតបន្តឹងពលករទេសន្តរប្រវេសន៍ធ្វើការខុសច្បាប់ក្នុងប្រទេសថៃ ចាប់ពីដើមខែកក្កដា ឆ្នាំ២០១៨មក និងទោះបីរាជរដ្ឋាភិបាលកម្ពុជា ក្នុងរយៈពេល៤ឆ្នាំកន្លងទៅនេះ បានផ្តល់ភាពស្របច្បាប់ដល់ពលករប្រមាណ ជាងមួយលានប្រាំមួយម៉ឺននាក់ ហើយក៏ដោយ ក៏ការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍មិនប្រក្រតីក៏នៅតែមានដដែល។

ពលរដ្ឋខ្មែរនៅតែបាននិងកំពុងចូលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ ជាបន្តទៅទៀត ទោះបីត្រូវជួបប្រទះបញ្ហាប្រឈម ហានីភ័យនានា ដូចជា ការបញ្ជូនត្រឡប់មកវិញ ការឃាត់ខ្លួន ការដាក់ទោសទណ្ឌពីអាជ្ញាធរប្រទេសថៃ រងការកេងប្រវ័ញ្ច ខាតបង់ប្រាក់កាស និងពេលវេលាជាដើម។ល។ ប្រជាពលរដ្ឋមួយចំនួននៅតែចាញ់ឧបាយកលមេខ្យល់បោកប្រាស់ ដែលប្រើរូបភាពជាភ្នាក់ងារមានសមត្ថកិច្ចផ្តល់ឯកសារក្លែងក្លាយ ជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ហើយទាមទារកម្រៃខ្ពស់ពីពលករ ឬជាអ្នកជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនទៅរកការងារក្រៅប្រទេស មានប្រាក់ខែច្រើន។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ និងអន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

ការអនុវត្តយុទ្ធសាស្ត្រ នៃផែនការសកម្មភាពជាតិ (២០១៤-២០១៨)

### ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

ក.១. សេចក្ដីព្រាងច្បាប់ដែលកំពុងរៀបចំ៖

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្ដីព្រាងច្បាប់ ស្ដីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្ដីព្រាងច្បាប់៖
    - ស្ដីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA)
    - ស្ដីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

ក.២. សន្ធិសញ្ញាកំពុងរៀបចំ៖

- ក្រសួងយុត្តិធម៌ បានរៀបចំសេចក្ដីព្រាងសន្ធិសញ្ញា ទ្វេភាគី៖
    - ស្ដីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលបារាំង
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលកូរ៉េខាងត្បូង។
    - ស្ដីពី "បញ្ជូនទណ្ឌិត"
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលអង់គ្លេស
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប៉េរូ
        - ✓ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ។

ក.៣. អនុស្សរណៈកំពុងរៀបចំ៖

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។
- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រី លើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្ដីពី "ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី" នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

ក.៤. បទដ្ឋានគតិយុត្ត កំពុងរៀបចំ៖

- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ៖ ធ្វើសេចក្ដីព្រាងលិខិតបទដ្ឋានគតិយុត្ត "សម្រាប់អនុវត្តល័ក្ខខ័ណ្ឌ ការងារកម្មករការងារផ្ទះ"។
- ក្រសួងអប់រំ យុវជន និងកីឡា៖ ធ្វើសេចក្ដីព្រាងគោលនយោបាយ ស្ដីពី "កិច្ចការការពារកុមារតាមសាលារៀន"។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្ដីព្រាងរៀបចំអនុក្រឹត្យ ស្ដីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។ [illegible]

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. កាត់បន្ថយភាពងាយរងគ្រោះដល់ជនមុខសញ្ញាងាយរងគ្រោះ

រដ្ឋបាលខេត្តចំនួន៣ គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែនថៃ បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ សរុបចំនួន ៨.៧៩៥ក្បាល ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មានៈ

- ខេត្តបាត់ដំបង ចំនួន ៥.២៩០ក្បាល
- ខេត្តបន្ទាយមានជ័យ ចំនួន ២.៥២០ក្បាល
- ខេត្តប៉ៃលិន ចំនួន ៩៨៥ក្បាល។

### ខ.២. ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

នៅខែតុលា ឆ្នាំ២០១៨នេះ **ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ** មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចសហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោបាយ **"ភូមិ-ឃុំ មានសុវត្ថិភាព"** ដល់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ បានចំនួន ៣.៧២១លើក មានអ្នកចូលរួមសរុបចំនួន ៣១៨.៨៣៧នាក់ (បើប្រៀបធៀបនឹងខែកញ្ញា មានចំនួន ២២៦.៩៣៩នាក់) មានការកើនឡើងចំនួន ៩១.៨៩៨នាក់ ស្មើនឹង ៤០,៤៩% ក្នុងនោះស្ត្រីមានចំនួន ១៨៥.១៩០នាក់។ (**ឧបសម្ព័ន្ធទី១**)

### ខ.៣. ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

- **ថ្នាក់រាជធានី ខេត្តៈ**

  បានចូលរួមផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធ នឹងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមប៉ុស្តិ៍វិទ្យុ សរុបចំនួន **៣៣លើក** ក្នុងនោះខេត្តៈ

  - ខេត្តកោះកុង ចំនួន ៣១លើក
  - ខេត្តសៀមរាប ចំនួន ០២លើក។

- **អង្គការដៃគូៈ**

  អង្គការ សាម៉ារីតាន់ភឺស បានសហការជាមួយសមត្ថកិច្ច ចែកខិត្តប័ណ្ណផ្សព្វផ្សាយអប់រំ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករចំណាកស្រុកចំនួន ៤០នាក់ (ស្រី ០៩នាក់) ដែលបញ្ជូនត្រឡប់ពីព្រំដែន តាមច្រកដូង ខេត្តបាត់ដំបង។

### ខ.៤. វិធានការបង្ការ ទប់ស្កាត់ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ

#### ខ.៤.១. វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទៈ

សាលាខេត្ត នគរបាលជំនាញ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត មន្ទីរចំណុះខេត្ត បានសហការជាមួយ ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្តៈ**

- កម្លាំងជំនាញអនុវត្ត នៃស្នងការដ្ឋាននគរបាលខេត្តៈ តាកែវ កែប មណ្ឌលគិរី ស្វាយរៀង កណ្តាល និងរតនគិរី បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន ៣៧៥គោលដៅ មានមនុស្សចំនួន ១.៦៦២នាក់ (ស្រី ១.២៧៨នាក់)។

- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ៦៦គោលដៅ សរុបចំនួន ៧៥គោលដៅទូទាំងរាជធានី-ខេត្ត។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន ៤០លើក ខេត្តអនុវត្តមានៈ ស្វាយរៀង ព្រះវិហារ ឧត្តរមានជ័យ កែប កំពង់ស្ពឺ និងព្រៃវែង។

- **អង្គការដៃគូៈ**

- **អង្គការម្លប់តាប៉ាង ខេត្តព្រះសីហនុ** ដើម្បីការពារសុវត្ថិភាពកុមារ បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បីចំនួន ១៤៣នាក់ ផ្ទះសំណាក់ សណ្ឋាគារ ២៤កន្លែង អ្នកលក់តាមឆ្នេរសមុទ្រ ៧១នាក់ បណ្តាញតាមសហគមន៍ ៦០នាក់ ផ្នែកភ្នាក់ងារទេសចរណ៍ ០២នាក់ សមាជិកបណ្តាញដែលជាបុគ្គលិកផ្ទះសំណាក់/សណ្ឋាគារ ៣៧៤នាក់។

- **អង្គការ Friend International ខេត្តសៀមរាប** បានអនុវត្តសកម្មភាពលើការងារការពារសុវត្ថិភាពកុមារ ដោយបានគៀងគរភ្នាក់ងារពីបណ្តាសហគមន៍ ក្នុងការទទួលខុសត្រូវដើម្បីការពារកុមារ សរុបចំនួន ២៦២នាក់ ដែលមកពីសហគមន៍ម៉ូតូរឺម៉កកង់បី បុគ្គលិកសណ្ឋាគារ បុគ្គលិកអង្គការ និងអាជ្ញាធរមូលដ្ឋាន ក្នុងការកំណត់សម្គាល់ និងការពារកុមារពីការរំលោភបំពានគ្រប់ទម្រង់ ទាំងអស់រួមមានៈ
  - ចំនួនកុមារ និងយុវវ័យទទួលបានការការពារដោយផ្ទាល់ ចំនួន ២៨១នាក់ (ស្រី ១៣១នាក់)
  - ចំនួនអ្នកហៅចូលទូរស័ព្ទបន្ទាន់ ចំនួន ៣០១នាក់ (ស្រី ១៩៦នាក់)
  - ចំនួនកុមារ និងយុវវ័យ ទទួលបានការការពារពីភ្នាក់ងារសុវត្ថិភាពកុមារ ចំនួន ១៥៣នាក់ (ស្រី ៧៣នាក់)។

## ខ.៥. វិធានការការប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់

### ខ.៥.១. វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក

- ការធ្វើបច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស សរុបចំនួន ៣៦១.១៥១នាក់ (ស្រី ១៦១.៤៤០នាក់) អនីតិជន ៩.៤២៧នាក់ (ស្រី ៣.៥៤២នាក់) ក្នុងនោះស្របច្បាប់ចំនួន ១៩៩.៩០៥នាក់ (ស្រី ៩៥.០៥៩នាក់) អនីតិជន ៦៥៣នាក់ (ស្រី ២៧៧នាក់) មិនស្របច្បាប់ចំនួន ១៦១.២៤៦នាក់ (ស្រី ៦៦.៣៨១នាក់) អនីតិជន ៨.៧៧៤នាក់ (ស្រី ៣.២៦៥នាក់) បើប្រៀបធៀបនឹងខែមុន គឺខែកញ្ញាមានចំនួន ៣៦២.៤៩៥នាក់ ថយចុះចំនួន ១.៣៤៤នាក់ ស្មើនឹង ០,៣៧%។

## ខ.៦. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈ ការរៀបអាពាហ៍ពិពាហ៍ខ្មែរ និងជនបរទេស

ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន ១១៥គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរ ចំនួន ១៦នាក់ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

## គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះ ទទួលបានពីអង្គភាពចំនួន៦ គឺៈ (១)នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ (២)កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្តៈ (៣)រាជធានីភ្នំពេញ (៤)ខេត្តកណ្តាល (៥)ខេត្តក្រចេះ និង(៦)ខេត្តត្បូងឃ្មុំ។

### គ.១. ការងារអនុវត្តច្បាប់

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន ០៧ករណីលើ១៥ករណី (បើប្រៀបធៀបនឹងខែកញ្ញា ថយចុះ ០៨ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ១០នាក់ (ស្រី ០៤នាក់) ជនសង្ស័យជាអនីតិជន ០១នាក់ និងជាជនបរទេស ០១នាក់ (សញ្ជាតិចិន)។ សង្គ្រោះជនរងគ្រោះ ចំនួន ០៩នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ ០៣នាក់ អាយុ១៥ឆ្នាំ-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ០៥នាក់ (ប្រគល់ឲ្យអង្គការ ០១នាក់ និងប្រគល់ទៅគ្រួសារ ០៨នាក់)។

##### ១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០៥/០៥ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ០៨នាក់ (ស្រី ០៤នាក់) ជនសង្ស័យជាអនីតិជន ០១នាក់ និងជាជនបរទេស ០១នាក់ (សញ្ជាតិចិន)។ សង្គ្រោះជនរងគ្រោះចំនួន ០៧នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ ០១នាក់ អាយុ១៥ឆ្នាំ-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ០៥នាក់ (ប្រគល់ឲ្យអង្គការ ០១នាក់ និងប្រគល់ទៅគ្រួសារ ០៦នាក់។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោមៈ

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០២ (អនីតិ.១) | |
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០២ | ០៣ | |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ០១ | |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០២ | ចិន១ |
| *សរុប* | *០៥ ករណី* | *០៨ នាក់ (អនីតិ.១)* | *១ នាក់* |

##### ២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ០២/១០ករណី (បើប្រៀបធៀបនឹងខែកញ្ញា ថយចុះ ០៨ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ សង្គ្រោះជនរងគ្រោះចំនួន ០២នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ ០២នាក់ (ប្រគល់ទៅគ្រួសារ ០២នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោមៈ

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ |
|---|---|---|
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ |
| *សរុប* | *០២ ករណី* | *០២ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

ឃ.១.១. ការទទួលជនសង្ស័យរងគ្រោះ

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែរសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស តាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស និងបានសហការជាមួយអង្គការដៃគូ មានចំនួន ២៦នាក់ (ស្រី ១៧នាក់) ក្នុងនោះមកពី៖

| | | |
|---|---|---|
| - ប្រទេសម៉ាឡេស៊ី | ចំនួន ១១នាក់ | (ស្រី ០៣នាក់) |
| - ប្រទេសចិន | ចំនួន ១១នាក់ | (ស្រី ១១នាក់) |
| - ប្រទេសឡាវ | ចំនួន ០២នាក់ | (ស្រី ០១នាក់) |
| - ប្រទេសសឹង្ហបុរី | ចំនួន ០២នាក់ | (ស្រី ០២នាក់)។ |

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍

អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ៩៨លើក មនុស្សចំនួន ១.៧១៦នាក់ (ស្រី ៥៦៧នាក់ កុមារ ១៣៧នាក់)។ ក្នុងនោះតាម៖

- ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ចំនួន ២៥លើក មនុស្សចំនួន ៦៦នាក់ (ស្រី ៣១នាក់)
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន ៧២លើក មនុស្សចំនួន ១.៦១៩នាក់ (ស្រី ៥១៦នាក់ កុមារ ១៣៧នាក់)។
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម ចំនួន ០១លើក មនុស្សចំនួន ៣១នាក់ (ស្រី ២០នាក់)។

- អគ្គស្នងការដ្ឋាននគរបាលជាតិ

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានទទួលពលករខ្មែររងគ្រោះ ដែលបញ្ជូនត្រឡប់ពីបណ្តាប្រទេសនានា សរុបចំនួន ០៣នាក់ (ស្រី ០២នាក់) តាមការសម្ភាសន៍បានឲ្យដឹងថាទៅតាមរយៈមេខ្យល់ទាំងអស់។ ក្នុងនោះមាន៖

| | | |
|---|---|---|
| - ប្រទេសវៀតណាម | ចំនួន ០២នាក់ | (ស្រី ០២នាក់) |
| - ប្រទេសចិន | ចំនួន ០១នាក់។ | |

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាសរុបចំនួន ០៨នាក់ (ស្រី)។ មានដូចខាងក្រោម ៖

- បានទទួលជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា ចំនួន ០៧នាក់ (ស្រី) ក្នុងនោះមកពី៖ ប្រទេសវៀតណាម(ឆ្លងដែនទៅចិន) ០៤នាក់ ចិន ០២នាក់ និងម៉ាឡេស៊ី ០១នាក់ ជាករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ ០៦នាក់ និងជួញដូរកម្លាំងពលកម្ម ០១នាក់។

- មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានទទួលជនរងគ្រោះធ្វើមាតុភូមិនិវត្តន៍ ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ពីប្រទេសថៃ (DSDW) ចំនួន ០១នាក់ (កុមារី) ជាករណីជួញដូរកម្លាំងពលកម្ម។

ឃ.២. <u>ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស</u>

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិម្បទាចំនួន ៣១នាក់ (ស្រី) ដូចមានខាងក្រោម៖

- បានធ្វើការសម្ភាស និងផ្តល់សេវាពិគ្រោះយោបល់នារីរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ០៧នាក់ រួចបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូដូចជាៈ អង្គការរតនៈអ៊ិនធើណេសិនណល អង្គការសម្ព័ន្ធចាប់ដៃ និងអង្គការសួននៃក្តីសង្ឃឹមនៅកម្ពុជា។
- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានបញ្ជូនជនរងគ្រោះ ដែលបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ ចំនួន ០១នាក់ (កុមារី) ទៅអង្គការ A21 ដើម្បីទទួលសេវាអប់រំក្នុង និងក្រៅប្រព័ន្ធ និងសេវាផ្សេងៗទៀតមុនពេលធ្វើសមាហរណកម្មត្រឡប់ទៅផ្ទះវិញ។
- **មន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ** បានធ្វើការពិគ្រោះយោបល់ និងបញ្ជូនស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ១០នាក់ (ស្រី ០៨នាក់ កុមារី ០២នាក់) ទៅទទួលសេវានៅអង្គការដៃគូ។
- **មន្ទីរសង្គមកិច្ចខេត្តក្រចេះ** បានបញ្ជូននារីរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ១៣នាក់ ទៅទទួលសេវាអង្គការដៃគូ។

ឃ.៣. <u>ការធ្វើសមាហរណកម្មជួយជនរងគ្រោះ និងជនងាយរងគ្រោះ</u>

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- បានសមាហរណកម្មជនងាយរងគ្រោះដោយអំពើជួញដូរកម្លាំងពលកម្មចំនួន ០៣នាក់ (ស្រី ០១នាក់ កុមារី ០២នាក់) ជាករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ (ឆ្លងកាត់តាមប្រទេសវៀតណាមទៅប្រទេសចិន) ដោយមានកិច្ចសហការជាមួយអង្គការរតនៈអ៊ិនធើណេសិនណល ក្នុងការផ្តល់សេវា និងជូនជនងាយរងគ្រោះត្រឡប់ទៅស្រុកកំណើតវិញ។

## <u>របាយការណ៍ពីស្ថានភាព៖</u>

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ**

**ស្នងការដ្ឋាននគរបាលខេត្ត** បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាត់បញ្ជូនត្រឡប់មកកម្ពុជាវិញ បានចំនួន ៦៥លើក មនុស្សចំនួន ១.៥១១នាក់ (ស្រី ៤៦១នាក់) អនីតិជន ១៥១នាក់ ក្នុងនោះមាន៖

+ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ៖

- ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ចំនួន ៥៤លើក មនុស្សចំនួន ១.៤៣២នាក់ (ស្រី ៤២៧នាក់) អនីតិជន ១២៧នាក់។
- ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង ចំនួន ១០លើក មនុស្សចំនួន ៤៨នាក់ (ស្រី ១៤នាក់)។

+ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម៖

- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀងចំនួន ០១លើក មនុស្សចំនួន ៣១នាក់ (ស្រី ២០នាក់) អនីតិជន ២៤នាក់។

- **អគ្គបញ្ជាការដ្ឋានទីចាត់ការ ការងារព្រំដែន នៃក្រសួងការពារជាតិ**

ដោយឡែក **អគ្គបញ្ជាការដ្ឋានទីចាត់ការ ការងារព្រំដែន** បានទទួល និងសម្ភាសន៍ពលករខ្មែរដែលអាជ្ញាធរថៃបញ្ជូនមកវិញ តាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃចំនួន ១.៦៦៤នាក់ (ស្រី ៥៨១នាក់) អនីតិជន ១៧៨នាក់ ក្នុងនោះមាន៖

- ច្រកអន្តរជាតិប៉ោយប៉ែត ចំនួន ១.៦១១នាក់ (ស្រី ៥៦៦នាក់) អនីតិជន ១៧៨នាក់
- ច្រកអន្តរជាតិដូង ចំនួន ៥២នាក់ (ស្រី ១៥នាក់)
- ច្រកអន្តរជាតិជាំ ចំនួន ០១នាក់។

## ការគ្រប់គ្រងជនបរទេស៖

**អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានបង្ហាញថាមានជនបរទេសដែលល្មើសច្បាប់ ត្រូវបានរកឃើញដូចខាងក្រោម ៖

១. ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់: ជនបរទេសដែលល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញពីព្រះរាជាណាចក្រកម្ពុជា មានចំនួន **៥៧**លើក មនុស្សចំនួន ៨០នាក់ (ស្រី ១៤នាក់) មាន ៤១សញ្ជាតិ ត្រូវបានបណ្តេញចេញដោយ ៖

- អគ្គនាយកដ្ឋាន ចំនួន ២៩លើក មនុស្សចំនួន ៥០នាក់ (ស្រី ០៨នាក់) មាន ១៦សញ្ជាតិ។
- បដិសេធមិនឲ្យចូលប្រទេស តាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ និងក្រុមផ្តល់ទិដ្ឋាការ ចំនួន ២៨លើក មនុស្សចំនួន ៣០នាក់ (ស្រី ០៦នាក់) មាន ២៥សញ្ជាតិ។

២. ករណីស្នាក់នៅខុសច្បាប់

- ហួសទិដ្ឋាកា ០១លើក មនុស្សចំនួន ០២នាក់ (ស្រី ០១នាក់) សញ្ជាតិស្រីលង្ការ។
- គ្មានឯកសារគ្រប់គ្រាន់ ០២លើក មនុស្សចំនួន ២៨នាក់ មាន ០២សញ្ជាតិ (វៀតណាម ២២នាក់ និងឡាវ ០៦នាក់)។
- គ្មានលិខិតឆ្លងដែន ០១លើក មនុស្សចំនួន ០១នាក់ សញ្ជាតិរុស្សី។

៣. ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី

- ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ពីជនបរទេសបែបអន្តោប្រវេសន៍សរុបចំនួន ១៤៣គ្រួសារ មនុស្សចំនួន ៤៦៣នាក់ (ស្រី ២៣៣នាក់) សញ្ជាតិវៀតណាម ក្នុងនោះដកហូតឯកសារ បានចំនួន ៣៣៧ឯកសារ មាន ០៦ប្រភេទឯកសារ។

# III. ការលើកកម្ពស់សមត្ថភាព

## ក. ក្នុងប្រទេស

ក.១. ការងារបណ្តុះបណ្តាលក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័នអនុវត្ត និងលេខាធិការដ្ឋាន រាជធានី-ខេត្ត បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ

បើកវគ្គបណ្តុះបណ្តាលបានចំនួន ០៩វគ្គ មានសិក្ខាកាមចូលរួមចំនួន ៣៤៩នាក់ ក្នុងនោះមានស្ត្រី ៧៦នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិក គ.ខ.ប.ជ ៖

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គលេខាធិការរង ក្រុមជំនួយកិច្ចការអនុវត្តច្បាប់ បានអញ្ជើញចូលរួមឧទ្ទេសក្នុងវគ្គបំប៉នជំនាញ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ដល់កងរាជអាវុធហត្ថ។ | ០១ | ៧០ | |
| ២ | **អគ្គស្នងការដ្ឋាននគរបាលជាតិ**<br>- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយអង្គការ AIM SWAT បើកវគ្គបណ្តុះបណ្តាល ស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើប្រាស់អាវុធ។ | ០១ | ២០ | ០១ |
| ៣ | **ខេត្តត្បូងឃ្មុំ** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានសហការជាមួយអង្គការសម្រាលទុក្ខមនុស្សជាតិកម្ពុជា បើកវគ្គបណ្តុះបណ្តាល ស្តីពីបែប បទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណ ដើម្បីផ្តល់សេវាសមស្របជូនជនរងគ្រោះ នៅសាលាស្រុកពញាក្រែក។ | ០១ | ៣៥ | ០៧ |
| ៤ | **លេខាធិការដ្ឋាន (គ.ខ.ប.ជ)** បានសហការជាមួយ**អង្គការវីនរ៉ក់អន្តរជាតិ** រៀបចំវគ្គបណ្តុះបណ្តាល៖<br>- ស្តីពីការពង្រឹងសមត្ថភាពជនបង្គោល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា (ស្រុកមណ្ឌលសីមា អ្នកចូលរួមចំនួន ៤២នាក់ ស្រី២៥នាក់)<br>- ស្តីពីការពង្រឹងសមត្ថភាពជនបង្គោល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា (រដ្ឋបាលស្រុកស្រែអំបិល អ្នកចូលរួមចំនួន ៤៧នាក់ ស្រី០៩នាក់)<br>- ស្តីពីការពង្រឹងសមត្ថភាពជនបង្គោល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា (សាលាឃុំបឹងព្រាវ ស្រុកស្រែអំបិល អ្នកចូលរួមចំនួន ៣១នាក់ ស្រី០៧នាក់)<br>- ស្តីពីការពង្រឹងសមត្ថភាពជនបង្គោល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា (ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល អ្នកចូលរួមចំនួន ២៦នាក់ ស្រី០៧នាក់)<br>- ស្តីពីការពង្រឹងសមត្ថភាពជនបង្គោល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា (ឃុំដងពែង ស្រុកស្រែអំបិលអ្នកចូលរួមចំនួន ៥២នាក់ ស្រី១៤នាក់)<br>- ស្តីពីការពង្រឹងសមត្ថភាពជនបង្គោល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា (ឃុំជីខក្រោម ស្រុកស្រែអំបិល អ្នកចូលរួមចំនួន ២៦នាក់ ស្រី០៦នាក់)។ | ០៦ | ២២៤ | ៦៨ |
| | **សរុប** | **០៩** | **៣៤៩** | **៧៦** |

ក.២. <u>សិក្ខាសាលា</u>

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបើកសិក្ខាសាលា ស្តីពីប្រព័ន្ធប្រមូលព័ត៌មានដៃគូអភិវឌ្ឍលើសេវាកម្ម សម្រាប់ជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងកេងប្រវ័ញ្ចផ្លូវភេទ សិក្ខាកាមចូលរួមចំនួន ៧០នាក់ មកពីតំណាងអង្គការដៃគូអភិវឌ្ឍន៍ចំនួន ៤៦ នៅភោជនីយដ្ឋានទន្លេបាសាក់២។

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំសិក្ខាសាលា ចំនួន ០១វគ្គ លើគោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅស្រុកចម្ការលើ ខេត្តកំពង់ចាម ដែលមានសិក្ខាកាមចូលរួមសរុប ៦៨នាក់ (ស្រី ២០នាក់) សមាសភាពមានដូចជាៈ មន្ត្រីថ្នាក់ស្រុក មន្ទីរស.អ.យស្រុក មេឃុំ មេភូមិ មន្ត្រីគ.ក.ន.ក គ្រូបង្រៀន គ្រូពេទ្យ និងប៉ូលិសប៉ុស្តិ៍។

ក.៣. ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៣៩លើក មានអ្នកចូលរួមសរុប ៦៨៥នាក់ (ស្រី ២៦៤នាក់) ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ១៩លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចំនួន ០៥លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន ១៥លើក។ (**ឧបសម្ព័ន្ធទី២**)

## ខ. ក្រៅប្រទេស និងថ្នាក់អន្តរជាតិ

ខ.១. កិច្ចប្រជុំ វគ្គបណ្តុះបណ្តាល និងសិក្ខាសាលា ជាអន្តរជាតិ

- ថ្នាក់ជាតិៈ
  - អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
    លោកជំទាវ ឧត្តមសេនីយ៍ទោ **វ៉ន សិរីលក្ខិណា** បានចូលរួមបណ្តុះបណ្តាលវគ្គខ្លីដោយJICA នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ស្តីពីការពង្រឹងបណ្តាញការងាររបស់ប្រទេសអាស៊ានលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានការចូលរួមពីប្រទេស ក្នុងអាស៊ានចំនួន៨ ដែលមានសិក្ខាកាមសរុបចំនួន ១៣នាក់។
- ថ្នាក់រាជធានី ខេត្តៈ
  - ខេត្តស្វាយរៀង
    បានធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំទ្វេភាគី ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការការពារកុមារឆ្លងដែន រវាងខេត្តស្វាយរៀង នៃព្រះរាជាណាចក្រកម្ពុជា ខេត្តឡុងអាន ខេត្តតៃនិញ និងទីក្រុងហូជីមិញ នៃប្រទេសវៀតណាម អ្នកចូលរួមចំនួន ៧២នាក់ (ស្រី ១២នាក់) នៅខេត្តស្វាយរៀង។

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់ៈ

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជាៈ

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នា ជាប្រព័ន្ធ និងបែងចែកការទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាព បើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃ សកម្ម ហើយកិត្តិយសក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាព បានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រីធ្វើរបាយការណ៍មិនយល់ ឬមិនបានសរសេរអស់នូវសកម្មភាព និងទិន្នន័យដែល ក្រសួង ស្ថាប័ន ឬអង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនអស់តាមរបាយការណ៍នោះដែរ។

## គ.សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូរត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនិមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។

- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V.ទិសដៅខែវិច្ឆិកា ឆ្នាំ២០១៨

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដេកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣.ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.........................ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី...០៥...ខែមករា...ឆ្នាំ២០១៨

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈ ខែតុលា ឆ្នាំ២០១៨

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាពដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 47 លើក | 5,728 នាក់ | 2,842 នាក់ |
| 2 | ខេត្តកណ្តាល | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 263 លើក | 9,129 នាក់ | 5,047 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការការប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្ស និងបញ្ជ្រាបតាមកិច្ចប្រជុំនានាដល់អាជ្ញាធរមូលដ្ឋាន លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | ក្រុមការងារថ្នាក់ស្រុក និង មន្ទីរអប់រំយុវជន និងកីឡា | 123 លើក | 4,263 នាក់ | 2,880 នាក់ |
| 3 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្តីពីការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 265 លើក | 53,967 នាក់ | 28,533 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | | 325 លើក | 13,143 នាក់ | 7,186 នាក់ |
| 4 | ខេត្តពោធិ៍សាត់ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 133 លើក | 18,703 នាក់ | 10,419 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅតាមវិទ្យាល័យ អនុវិទ្យាល័យទាំង២០ ទូទាំងខេត្តពោធិ៍សាត់ សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ។ | ស្នងការដ្ឋាននគរបាលខេត្ត | 670 លើក | 121,445 នាក់ | 73,155 នាក់ |
| 5 | ខេត្តសៀមរាប | ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ទូទាំង១២ក្រុង-ស្រុក។ | ស្នងការដ្ឋាននគរបាលខេត្ត | 292 លើក | 13,717 នាក់ | 8,896 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | មន្ទីរអប់រំ មន្ទីរកិច្ចការនារី ស្នងការដ្ឋាននគរបាលខេត្ត និងរដ្ឋបាលស្រុក | 45 លើក | 3,020 នាក់ | 2,101 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | រដ្ឋបាលស្រុក | 27 លើក | 1,066 នាក់ | 638 នាក់ |
| 6 | ខេត្តកំពង់ឆ្នាំង | វេទិកាសាធារណៈផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 424 លើក | 17,712 នាក់ | 10,827 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| | | ផ្សព្វផ្សាយ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបការយល់ដឹងតាមរយៈកិច្ចប្រជុំនានា ដល់ប្រជាពលរដ្ឋ កម្មករនិយោជិត និងយុវជន។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំខេត្ត មន្ទីរការងារខេត្ត | 18 លើក | 485 នាក់ | 161 នាក់ |
| | | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ៩យ៉ាង អំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងបញ្ជ្រាប ច្បាប់ស្តីពីការជួញដូរមនុស្ស ដល់ ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 507 លើក | 30,733 នាក់ | 17,290 នាក់ |
| 7 | ខេត្តកំពង់ចាម | ផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 220 លើក | 11,602 នាក់ | 6,473 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងនីតិវិធីទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស ដល់ប្រជាពលរដ្ឋ។ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គដៃគូ | 4 លើក | 335 នាក់ | 178 នាក់ |
| 8 | ខេត្តព្រះសីហនុ | ផ្សព្វផ្សាយតាមរៈកិច្ចប្រជុំ ស្តីការពង្រឹងសមត្ថភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ស្រុម មេបញ្ជាការ មេបញ្ជាការរង អធិការ អធិការរង មេប៉ុស្តិ៍ គ.ក.ន.កឃុំ មេភូមិ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីរកិច្ចការនារីខេត្ត | 3 លើក | 295 នាក់ | 136 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | ក្រុមការងារគ.ខ.ប.ជខេត្ត និងអាជ្ញាធរក្រុង/ស្រុក | 7 លើក | 332 នាក់ | 202 នាក់ |
| 9 | ខេត្តព្រះវិហារ | ផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថានខុសច្បាប់ ដល់កងកម្លាំងមន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 1 លើក | 130 នាក់ | 73 នាក់ |
| 10 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅតាមឃុំ សង្កាត់ ទូទាំងខេត្ត។ | ក្រុមការងារអធិការនគរបាលក្រុង ស្រុក | 9 លើក | 387 នាក់ | 177 នាក់ |
| 11 | ខេត្តកំពត | ផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅច្រកតន់ហាន់ ដល់ប្រជាពលរដ្ឋកម្ពុជា និងប្រជាពលរដ្ឋវៀតណាម។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 3 លើក | 32 នាក់ | 17 នាក់ |
| 12 | ខេត្តស្វាយរៀង | វេទិកាសាធារណៈ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលជាតិ | 330 លើក | 12,317 នាក់ | 7,751 នាក់ |
| 13 | ខេត្តក្រចេះ | ផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងមន្ទីរសង្គមកិច្ចខេត្ត | 5 លើក | 296 នាក់ | 208 នាក់ |

សកម្មភាពសរុបចំនួន: 3,721 លើក

មនុស្សសរុបចំនួន: 318,837 នាក់

ស្រីសរុបចំនួន : 185,190 នាក់

# ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៣៩លើក) មនុស្សចំនួន៦៨៥នាក់ (ស្រី២៦៤នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | សម្របសម្រួលចំនួន១៩លើក អ្នកចូលរួមចំនួន ១៧៤នាក់ ស្រី៣៩នាក់<br>- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបកិច្ចប្រជុំបូកសរុបរបាយការណ៍ឆមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** អ្នកចូលរួមចំនួន ៥៩នាក់ ស្រី **១៧**នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការប្រគល់ភារកិច្ចនៅក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីពង្រឹងរបៀបរបការងារ វឌ្ឍនភាពការងារនៅក្នុងអង្គភាព និងស្តីពីការត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៨ អ្នកចូលរួមចំនួន១០៨នាក់ ស្រី២២នាក់ (ចំនួន០៥លើក) នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានដឹកនាំមន្ត្រីក្រុមការងារជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បើកកិច្ចប្រជុំ ស្តីពីការណែនាំការងារសម្រាប់ថ្ងៃ១២ ធ្នូ សម្រាប់ក្រុមការងារពិធីការ បដិសណ្ឋារកិច្ច និងសិល្បៈ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>១ . <u>ក្រុមជំនួយការបង្ការ ទប់ស្កាត់:</u><br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ុន វ៉ូ** អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ តំណាងឲ្យអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សារៀបចំជំនួយស្មារតីត្រៀមសម្រាប់ **សម្តេចក្រឡាហោម** ជួបជាមួយលោកស្រី **រ៉ូណា ស្មីត** បេសកជនពិសេស ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា របស់អង្គការសហប្រជាជាតិ ក្នុងការត្រៀមឆ្លើយតបទៅនឹងរាល់បណ្តាសំណួរ ចម្លើយ ដែលពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ដឹកនាំកិច្ចប្រជុំដោយ ឯកឧត្តម **ប៊ុន ហុន** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ នៅសាលប្រជុំ អគារ A ក្រសួងមហាផ្ទៃ។<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ស៊ុន វ៉ូ** អគ្គលេខាធិការរង ទទួលបន្ទុកក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានដឹកនាំកិច្ចប្រជុំស្តីពី ការបែងចែកការទទួលខុសត្រូវរបស់ក្រុមការងារផ្គត់ផ្គង់ និងដឹកជញ្ជូន យោងតាមលិខិតបង្គាប់ការលេខ២០៣/១៨ ល.ប.ក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ ស្តីពីការចាត់តាំងក្រុមជំនួយការជួយការងារ រៀបចំទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៨។<br>២. <u>ក្រុមការងារអនុវត្តច្បាប់</u><br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** បានដឹកនាំក្រុមជំនួយកិច្ចការអនុវត្តច្បាប់ និងក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ដើម្បីស្វែងរកចំណាត់ការលើករណីវីដេអូផ្សព្វផ្សាយលើបណ្តាញសង្គមដែលមានខ្លឹមសារថា ម្តាយបានលក់កូនស្រី។<br>- ឯកឧត្តម ឧត្តមសេនីយ៍ឯក **ជីវ ផល្លី** អគ្គលេខាធិការរង បានចូលរួមប្រជុំគណៈកម្មការប្រឹក្សាការងារអាណត្តិទី៨ លើកទី១៩ ស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករ និយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៩។ |

**៣. ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**

- បានចូលរួមកិច្ចប្រជុំជាមួយមេធាវី ទាក់ទងទៅនឹងករណីស្ត្រីពពោះជំនួស ៣២នាក់ ដើម្បីឲ្យពួកគាត់បាននៅក្រៅឃុំ តាមនីតិវិធីរបស់តុលាការ។
- បានចូលរួមសន្និសិទថ្នាក់តំបន់ ស្តីពីសន្និសិទថ្នាក់តំបន់ឆ្ពោះទៅអនុវត្តយុទ្ធសាស្ត្រ INSPIRE បញ្ចប់អំពើហិង្សាលើកុមារ នៅ HoTel Cambodiana រយៈពេល ៣ថ្ងៃ ចាប់ពីថ្ងៃទី៣០ ខែតុលា ដល់ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៨។
- បានស្រង់ទិន្នន័យពលរដ្ឋខ្មែររងគ្រោះនៅប្រទេសចិន ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ សរុបចំនួន ១៣នាក់ (ស្រី) រងគ្រោះដោយសារចាញ់បោកមេខ្យល់យកទៅរៀបការនៅចិនដោយខុសច្បាប់។

**៤. ក្រុមជំនួយកិច្ចការយុត្តិធម៌:**

- បានទំនាក់ទំនង ក្រសួងយុត្តិធម៌ ដើម្បីសុំរបាយការណ៍ប្រចាំខែ។

**៥. ក្រុមជំនួយកិច្ចការទំនាក់ទំនងអន្តរជាតិ:**

- លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** បានចូលរួមកិច្ចប្រជុំជាមួយ JICA ដើម្បីទទួលការណែនាំក្នុងការចេញដំណើរ និងការស្នាក់នៅប្រទេសជប៉ុន ក្នុងរយៈពេលបណ្តុះបណ្តាល។
- លោកជំទាវ ឧត្តមសេនីយ៍ទោ **រ៉ន សិរីលក្ខិណា** បានដឹកនាំកិច្ចប្រជុំ ក្រុមការងារអោយជី ដើម្បីរៀបចំឯកសារសំខាន់ៗ ប្រគល់ជូនការិយាល័យស្រាវជ្រាវព័ត៌មាន និងត្រួតពិនិត្យ ធ្វើការស្កេនរក្សាទុកជាឯកសារយោង និងរក្សាទុកប្រើប្រាស់នៅថ្ងៃក្រោយ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- លោកប្រធានក្រុមជំនួយការទំនាក់ទំនងអន្តរជាតិស្តីទី និងមន្ត្រីការិយាល័យស្រាវជ្រាវព័ត៌មាន និងត្រួតពិនិត្យ បានដឹកនាំកិច្ចប្រជុំ ដើម្បីធ្វើបទបង្ហាញអំពីការប្រើប្រាស់បណ្តាញវីគី ដែលមានអ្នកចូលរួមចំនួន **០៧**នាក់ នៅបន្ទប់ប្រជុំលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។

**៦. ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍:**

- លោកអនុប្រធានក្រុមជំនួយកិច្ចការ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើកទី២ ស្តីពីការពិនិត្យបញ្ចប់លើសេចក្តីព្រាងគោលនយោបាយទេសន្តរប្រវេសន៍ការងារ ឆ្នាំ២០១៩-២០២៣ នៅសណ្ឋាគារភ្នំពេញ។
- លោកអនុប្រធានក្រុមជំនួយកិច្ចការ បានចូលរួមសិក្ខាសាលាត្រីភាគីត្រៀមថ្នាក់ជាតិ ដើម្បីរៀបចំឯកសារសម្រាប់ចូលរួមប្រជុំវេទិកាអាស៊ានលើកទី១១ ស្តីពីការលើកកម្ពស់ការងារសមរម្យ សម្រាប់ពលករទេសន្តរប្រវេសន៍កម្ពុជា នៅសណ្ឋាគារភ្នំពេញ។

**៧. លេខាធិការដ្ឋាន គ.ខ.ប.ជ៖**

- លិខិតរបស់ គ.ជ.ប.ជ៖ (លិខិតចេញចំនួន០៤ច្បាប់) (លិខិតចូលចំនួន១១ច្បាប់)
- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ (លិខិតចេញចំនួន២១ច្បាប់) (លិខិតចូលចំនួន០៦ច្បាប់)
- ស្រង់វត្តមានប្រចាំថ្ងៃ ដើម្បីតាមដានការងារប្រចាំថ្ងៃរបស់មន្ត្រី។
- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុនៅរៀងរាល់កិច្ចប្រជុំ។
- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែតុលា ឆ្នាំ២០១៨ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- បូកសរុបរបាយការណ៍ប្រចាំខែតុលា និងរបាយការណ៍រយៈពេល១០ខែ ឆ្នាំ២០១៨ របស់ គ.ជ.ប.ជ។
- ប្រមូលរបាយការណ៍តាមបណ្តាអន្តរក្រសួង ស្ថាប័ន និងរាជធានី-ខេត្តទាំង២៥។

| | |
|---|---|
| | - រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។<br>- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវិតី។<br>- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | - បានចាត់គ្រូឧទ្ទេសចូលរួមក្នុងវគ្គបណ្តុះបណ្តាលលើគោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តត្បូងឃ្មុំ អ្នកចូលរួមចំនួន ៤០នាក់ ស្រី ១១នាក់។<br>- បានចាត់មន្ត្រីចូលរួមកិច្ចប្រជុំនានា ចំនួន ០៣លើក និងចូលរួមសន្និសីទ ០១លើក។ |
| អគ្គនាយកដ្ឋានអន្តោប្រវេសន៍ | - បានអនុញ្ញាតឲ្យលោក Glen McEWen ប្រធានគ្រប់គ្រងតំបន់អាស៊ី និងសហការី នៃនគរបាលសហព័ន្ធអូស្រ្តាលី ដើម្បីចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។<br>- បានអនុញ្ញាតឲ្យ Fohn D.Wikson ជាសេនានុព័ន្ធច្បាប់ និងសហការី នៃការិយាល័យស៊ើបអង្កេតសហព័ន្ធសហរដ្ឋអាមេរិក ម្បីចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ១៥លើក អ្នកចូលរួមសរុបចំនួន ៤៧១នាក់ (ស្រី ២១៤នាក់)** | |
| ខេត្តកណ្តាល | - ក្រុមការងារថ្នាក់ក្រុង-ស្រុកទាំង១១ បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន ០៧លើក អ្នកចូលរួមចំនួន ១៥០នាក់ ស្រី ៨២នាក់។ |
| ខេត្តសៀមរាប | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបដឹកនាំកិច្ចប្រជុំប្រចាំត្រីមាសទី៣ ឆ្នាំ២០១៨ អ្នកចូលរួមចំនួន ៣៨នាក់ ស្រី ១៦នាក់។<br>- រដ្ឋបាលស្រុកក្រឡាញ់ បានរៀបចំ និងដំណើរកិច្ចប្រជុំប្រចាំខែតុលា ឆ្នាំ២០១៨ អ្នកចូលរួមចំនួន ៣៥នាក់ ស្រី ១៣នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានសម្របសម្រួលជូនប្រធានក្រុមការងារកិច្ចការអនុវត្តច្បាប់ និងប្រធានក្រុមការងារកិច្ចការទេសន្តរប្រវេសន៍ ដើម្បីចូលរួមជាវាគ្មិន ក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការកសាងសមត្ថភាពដល់ក្រុមជួយខ្លួនឯងពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស នៅរដ្ឋបាលស្រុកជីក្រែង រៀបចំដោយអង្គការក្រុមអ្នកស្ម័គ្រចិត្តស៊ីវិល (GVC)។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលជួបជាមួយក្រុមការងាររបស់អង្គការសកម្មភាពដើម្បីកុមារ ដើម្បីសិក្សាស្វែងយល់អំពីស្ថានភាពនៃការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ជាពិសេសពីសំណាក់ភ្ញៀវទេសចរ និងយន្តការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជា នៅបន្ទប់ប្រជុំសាលាខេត្តសៀមរាប។ |
| ខេត្តព្រះវិហារ | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ ស្តីអំពីការពិភាក្សា ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារទាំង៦ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន ១៨នាក់ ស្រី ០៨នាក់។ |
| ខេត្តកំពង់ធំ | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបរបាយការណ៍ត្រីមាសទី៣ ឆ្នាំ២០១៨ និងប្រជុំប្រកាសសមាសភាពគណៈកម្មាធិការ និងលេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត អ្នកចូលរួមចំនួ ២៧នាក់។ |
| ខេត្តកំពង់ចាម | - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមសិក្ខាសាលា ស្តីពីការគ្រប់គ្រងទេន្តរប្រវេសន៍ នៅមន្ទីរផែនការរយៈពេល៣ថ្ងៃ។ |
| ខេត្តបន្ទាយមានជ័យ | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែ អ្នកចូលរួមចំនួន ២៥នាក់ ស្រី០៨នាក់។ |
| ខេត្តប៉ៃលិន | - លោកជំទាវ អភិបាលរងខេត្ត បានចូលរួមសិក្ខាសាលា ស្តីពីការធ្វើចំណាកស្រុកខុសច្បាប់ នៅសង្កាត់បរយ៉ាខា ក្រុងប៉ៃលិន អ្នកចូលរួមចំនួន ១៧៨នាក់ ស្រី ៨៧នាក់។ |